គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទស្សនៈវិស័យ ៖ ដើម្បីការបោះឆ្នោតមានគុណភាព ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ

# ការរកឃើញលើការសង្កេតការអនុវត្តន៍ការចុះឈ្មោះបោះឆ្នោតសាកល្បង និងអនុសាសន៍ សម្រាប់ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦





កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ខុមហ្វ្រែលបានសហការជាមួយសម្ព័ន្ធកំណែទំរង់ការបោះឆ្នោត ហៅកាត់ថា ERA រៀបចំកិច្ចពិភាក្សាតុមូលមួយស្តីពី «ការរកឃើញលើការសង្កេតការអនុវត្តន៍ការចុះឈ្មោះបោះឆ្នោតសាកល្បង និងអនុសាសន៍សម្រាប់ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦» នៅឯសណ្ឋាគារសាន់វេ។ នៅក្នុងកម្មវិធីនោះមានការចូលរួមចំនួន៦៤នាក់(១៤នាក់ជាស្ត្រី)រួមមាន តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា តំណាង គ.ជ.ប ក្រសួងមហាផ្ទៃ គណបក្សនយោបាយ ស្ថានទូត សង្គមស៊ីវិលជាតិ និងអន្តរជាតិ អ្នកសារព័ត៌មាន និងអ្នកពាក់ព័ន្ធផ្សេងទៀត។ កម្មវត្ថុនៃកិច្ចពិភាក្សា គឺដើម្បីបង្ហាញពីរបាយការណ៍នៃការរកឃើញពីលើការសង្កេតការអនុវត្តន៍ការចុះឈ្មោះបោះឆ្នោតសាកល្បងឆ្នាំ២០១៥ របស់ គ.ជ.ប និងពិភាក្សាអំពីអនុសាសន៍ សម្រាប់ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ខុមហ្វ្រែលបានរកឃើញចំណុចវិជ្ជមានជាច្រើននៃការអនុវត្តន៍ការរបស់គ.ជ.បថ្មីរួមមាន៖

- ✓ បង្កើតប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មីមួយ ស្របទៅតាមច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ✓ ការប្រើប្រាស់កុំព្យូទ័រ ការថតរូប ជាមួយការផ្តិតស្នាមក្រយៅដៃ (ជីវមាត្រ) ការថតឯកសារអ្នកចុះឈ្មោះបោះឆ្នោត និងការបញ្ជូនទិន្នន័យតាមប្រព័ន្ធ Online ដែលបានសាកល្បងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥
- ✓ ការបង្កើត និងចែកចាយសេចក្តីព្រាង បទបញ្ជា និងនីតិវិធី សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី។

ទន្ទឹមនឹងនោះដែរ សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតក៏បានផ្តល់អនុសាសន៍មួយចំនួនដែលត្រូវតែមានការកែលម្អដើម្បីធានាប្រសិទ្ធភាព និងគុណភាពដែលរួមមាន៖

- ✓ គ.ជ.ប ត្រូវបើកចំហព័ត៌មានអំពីគម្រោងសកម្មភាព និងផែនការថវិកា

- ✓ ការពិគ្រោះយោបល់លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីចុះឈ្មោះបោះឆ្នោតឲ្យបានពេញលេញ និងគ្រប់ភាគីពាក់ព័ន្ធ
- ✓ ការកែលម្អការផ្ទៀងផ្ទាត់ទិន្នន័យអ្នកស្នើសុំចុះឈ្មោះបោះឆ្នោត
- ✓ កាត់បន្ថយកិច្ចការសរសេរដៃរបស់អនុប្រធានក្រុមចុះឈ្មោះបោះឆ្នោត
- ✓ ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលបានបោះពុម្ពចេញពីម៉ាស៊ីនព្រីន
- ✓ គ.ជ.ប គួរតែកំណត់នូវការធានាឲ្យបានច្បាស់លាស់លើគុណភាពបញ្ជីឈ្មោះបោះឆ្នោត យ៉ាងហោចណាស់ឲ្យមានភាពត្រឹមត្រូវបាន៩៨%
- ✓ គ.ជ.ប បន្ថែមនូវសេចក្តីណែនាំ ឬនីតិវិធីឲ្យបានច្បាស់ជាមួយការផ្តិតយកស្នាមក្រយៅមេដៃទាំងពីរ និងការថតរូប
- ✓ បន្ថែមសម្ភារៈ និងឧបករណ៍មួយចំនួន
- ✓ ពង្រឹងការងារជ្រើសរើសមន្ត្រីរបស់ គ.ជ.ប ឲ្យមានតម្លាភាព និងពេលវេលាគ្រប់គ្រាន់ និងព្រមទាំងកែលម្អនូវវិធីសាស្ត្របណ្តុះបណ្តាលសម្រាប់ក្រុមការងារចុះឈ្មោះបោះឆ្នោត។

តំណាងគ.ជ.ប ថ្មីមានការស្វាគមន៍ចំពោះអនុសាសន៍ និងមតិរិះគន់ដើម្បីស្ថាបនារបស់សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា និងសន្យាពាំនាំយកមតិយោបល់ និងអនុសាសន៍ទាំងនេះទៅជជែកជាមួយថ្នាក់ដឹកនាំ។ ជាមួយគ្នាមតិភាគច្រើនអង្គពិភាក្សាបានគាំទ្រចំពោះការរកឃើញនិងអនុសាសន៍របស់សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត។ កិច្ចពិភាក្សានេះបានប្រព្រឹត្តទៅយ៉ាងរលូនដូចការគ្រោងទុក។